ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ៨ រោច ខែ ជេស្ឋ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃកិច្ចពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោកជំទាវ Dr. Devyani Khobragade ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

***

នាព្រឹកថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២១, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាការងារតាមប្រព័ន្ធវីឌីអូជាមួយលោកជំទាវ Dr. Devyani Khobragade ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវកិច្ចស្វាគមន៍ និងអបអរសាទរចំពោះលោកជំទាវ Dr. Devyani Khobragade ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិការងាររបស់ជំទាវនៅកម្ពុជានាពេលនេះ ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសំដែងនូវការចូលរួមរំលែកការលំបាកដែលប្រជាជនឥណ្ឌាកំពុងប្រឈមនាពេលបច្ចុប្បន្ន ដោយសារការរាតត្បាតយ៉ាងខ្លាំងក្លានៃជំងឺកូវីដ-១៩ ហើយសង្ឃឹម និងជឿជាក់ថា កម្ពុជា-ឥណ្ឌា បន្តពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធទប់ស្កាត់នៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងក៏ដូចជាក្នុងវិស័យអាទិភាពនានា ទោះស្ថិតក្នុងកាលៈទេសៈដែលប្រទេសទាំងពីរ និងពិភពលោក កំពុងប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ ។

លោកជំទាវឯកអគ្គរដ្ឋទូត Dr. Devyani Khobragade បានសំដែងនូវអំណរគុណចំពោះការចូលរួមរំលែកការលំបាករបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រីជាមួយប្រជាជនឥណ្ឌា និងបានផ្តល់ដំណឹងថា បច្ចុប្បន្នស្ថានភាពជំងឺកូវីដ-១៩ នៅប្រទេសឥណ្ឌា មានលក្ខណៈប្រសើរជាងមុនជាបណ្តើរៗហើយ ។ ទោះបីស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកបែបនេះ រដ្ឋាភិបាលឥណ្ឌានៅតែបន្តរក្សាការសន្យារបស់ខ្លួនចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចសហការ លើការប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងខិតខំបន្តពង្រឹងនិងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងទៀតដូចជា ការសម្រួលពាណិជ្ជកម្មក្រៅប្រទេស ការជំរុញការវិនិយោគឯកជនពីឥណ្ឌាមកកម្ពុជា និងកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងវិស័យឌីជីថល តាមរយៈយន្តការនានា ដូចជាយន្តការទ្វេភាគី, យន្តការតំបន់ និងយន្តការឥណ្ឌា-អាស៊ាន ជាដើម ។

ជាមួយគ្នានេះ, លោកជំទាវឯកអគ្គរដ្ឋទូត **Dr. Devyani Khobragade** បានសំដែងនូវការកោតសរសើរចំពោះកម្ពុជាដែលសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុង១ឆ្នាំ នាពេលកន្លងមក និងបានប្រែក្លាយកម្ពុជាជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយក្នុងស្ថានភាពដ៏លំបាកនេះ លោកជំទាវឯកអគ្គរដ្ឋទូតមានបំណងចង់ស្វែងយល់អំពីវិធានការណ៍សង្គមនិងសេដ្ឋកិច្ចរបស់កម្ពុជាក្នុងការគ្រប់គ្រងវិបត្តិកូវីដ-១៩ ។

ជាមួយការអបអរសាទរចំពោះស្ថានភាពប្រសើរជាងមុននៃវិបត្តិកូវីដ-១៩ នៅប្រទេសឥណ្ឌា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានកោតសរសើរចំពោះសាធារណរដ្ឋឥណ្ឌាដែលមានសមត្ថភាពក្នុងការផលិតវ៉ាក់សាំងជំងឺកូវីដ-១៩ និងនៅតែបន្តរក្សាការសន្យារបស់ខ្លួនក្នុងកិច្ចសហការប្រយុទ្ធទប់ស្កាត់ជំងឺកូវីដ-១៩ នៅកម្ពុជា ជាពិសេស លោកជំទាវ **Dr. Devyani Khobragade** ផ្ទាល់ ដែលកន្លងមកបានខិតខំសហការនិងសម្របសម្រួលឱ្យមានការផ្គត់ផ្គង់វ៉ាក់សាំង AstraZeneca (Covidshield) ដល់កម្ពុជា ។ កម្ពុជានៅតែមានតម្រូវការវ៉ាក់សាំងបន្ថែមទៀត ហើយសង្ឃឹមថា ឥណ្ឌានឹងបន្តផ្គត់ផ្គង់វ៉ាក់សាំងបន្ថែមមកកម្ពុជានាពេល ដ៏ខ្លីខាងមុខ ។ នៅក្នុងការគ្រប់គ្រងវិបត្តិកូវីដ-១៩, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថា កម្ពុជាបានអនុវត្តនូវវិធានការ ***"រក្សាស្ថេរភាពសង្គម និងរក្សាភាពរស់រានមានជីវិតផ្នែកសេដ្ឋកិច្ច (Survival Economy)"*** របស់ប្រជាជនតាមរយៈកម្មវិធី ***"ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់"*** ដើម្បីជួយគាំទ្រប្រជាជនដែលមានកម្រិតជីវភាពទាប និងជួបប្រឈមនឹងការលំបាកក្រោយការអនុវត្តការបិទខ្ទប់ ។ លើសពីនេះ, រាជរដ្ឋាភិបាលកម្ពុជា កំពុងគិតគូរអំពីការដាក់ឱ្យអនុវត្តកម្មវិធីប្រហាក់ប្រហែលគ្នានេះ នៅក្នុងអន្តរកាលក្រោយបិទបញ្ចប់ព្រឹត្តិការណ៍ ២០ កុម្ភៈ ដើម្បីជួយដល់ប្រជាជនងាយរងគ្រោះអាចសម្របខ្លួនបានឡើងវិញក្នុងបរិបទនៃប្រក្រតីភាពថ្មី ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ក៏បានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះសាធារណរដ្ឋឥណ្ឌាដែលមានបំណងផ្តល់ហិរញ្ញប្បទានដល់កម្ពុជាក្នុងវិស័យឌីជីថល ស្របពេលដែលកម្ពុជាកំពុងមានតម្រូវការ ដោយកម្ពុជាទើបតែបានអនុម័តឯកសារ ***"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"*** និងត្រៀមរៀបចំឱ្យមានគោលនយោបាយពាក់ព័ន្ធនឹងវិស័យឌីជីថលផ្សេងទៀត នាពេលខាងមុខ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជំរុញ និងសម្រួលពាណិជ្ជកម្មទ្វេភាគី តាមរយៈខិតខំឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ឥណ្ឌានាពេលខាងមុខ ជាដើម ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានជូនពរចំពោះលោកជំទាវ **Dr. Devyani Khobragade** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌាប្រចាំនៅកម្ពុជា ឱ្យទទួលបាន ជោគជ័យគ្រប់ភារកិច្ចក្នុងអាណត្តិរបស់លោកជំទាវនៅកម្ពុជា ។

***